ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៩/០២៥ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញកៅស៊ូ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីលើកស្ទួយឧស្សាហកម្មកៅស៊ូនាំចេញ

### សម្រេច

**មាត្រា ១.-**

ត្រូវបានកែសម្រួលអត្រាអាករនាំចេញដែលគិតតាមរបៀប "ពន្ធគិតតាមឯកតា" លើមុខទំនិញជ័រកៅស៊ូ ដូចមានចែងក្នុងមាត្រា ១ នៃអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧ ដូចខាងក្រោម÷

- ពុំជាប់អាករនាំចេញ បើតម្លៃគិតអាករនាំចេញទាបជាង ១៤០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ២៥ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ១៤០០ ឡើង តែទាបជាង ១៨០០ ដុល្លារអាមេរិកក្នុង ១ តោន

- ជាប់អាករនាំចេញ ៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ១៨០០ ឡើង តែទាបជាង ២៥០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ១០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ២៥០០ ឡើង តែទាបជាង ៣៥០០ ដុល្លារអាមេរិកក្នុង ១ តោន
- ជាប់អាករនាំចេញ ២០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៣៥០០ ដុល្លារអាមេរិកក្នុង ១ តោន ឡើងទៅ។

**មាត្រា ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០ តទៅ។

ថ្ងៃ ចន្ទ ១១ រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
  *"ដើម្បីជូនជ្រាប"*
- ដូចមាត្រា ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ